# ស័ង្ខសិល្បជ័យ

## ភាគទី១១

បន្ទាប់ពីបានស្តាប់ហើយ បទុមាជឿថាអនាគតនៃបុត្រនឹងបានត្រាស់ជាព្រះពុទ្ធនាំសត្វលោកទៅរកសេចក្តីសុខ។

នេះនឹងនិយាយពីស្តេចពាលទាំងប្រាំមួយនាំកេសរសុមន្ទានិងបុត្រីសំដៅនគរបញ្ចាល។ កេសរសុមន្ទាជេរថា: "ពួកអស់ឯងនាំយើងទៅណា យើងចាំក្មួយយើង ស័ង្ខសិល្បជ័យដែលបានកាន់រាជអាជ្ញាទៅច្បាំងនឹងយក្សយកយើងមក ពួកអស់ឯងចេញពីណាមកឆក់យកយើងដូច្នេះ..."។ ពួកស្តេចពាលទាំងប្រាំមួយឆ្លើយទៅទាំងកំពោលថា: "យើងនាមទៅនគរបញ្ចាលអ្នកនឹកប្តីពេកឬ ទើបស្តីរវើរវាយថា មានស័ង្ខសិល្បជ័យឯណាទៅវិញ គឺមានតែពួកយើងទេដែលច្បាំងយកពីយក្សមក ហើយបើនៅរឹងទទឹង យើងនឹងកាត់ក្បាលយកទៅតែម្តង កុំឲ្យខុសអាជ្ញា"។ កេសរសុមន្ទាស្តាប់ហើយគិតថា: "បើរឹងទទឹងមិនថ្នមសំដីនឹងពួកវា សមស្លាប់ឥតការ"។ គិតហើយទើបស្រដីស្រួលវិញថា: "ក្មួយអើយ! មាតាចាញ់ហើយ ចិត្តស្រាលដូច្នេះចូរក្មួយកុំគិត ឥឡូវតើត្រូវនិយាយអ្វីប្រាប់មាតាមក នឹងផាលនិយាយបានដូចគ្នា..."។ ពួកស្តេចពាកលទាំងប្រាំមួយគិតស្មានថា កេសរសុមន្ទាត្រូវជាមួយ ក៏រ៉ាយរ៉ាប់រឿងទាំងអស់ប្រាប់ដោយឥតលាក់បាំង។ ចំណែកកេសរសុមន្ទាធ្វើជាសើចលេង ហាក់ដូចជាភ្លេចស័ង្ខសិល្បជ័យ។

លុះទៅដល់នគរស្តេចពាលខ្លះក៏ចូលទៅទូលបិតាមុន ព្រះអង្គសេនាកុត្តរាជទ្រង់សណ្តាប់រួច សោមនស្សពេកក្រៃទ្រង់ចាត់ឲ្យមន្ត្រីអ្នកមុខអ្នកការ រៀបចំដង្ហែរអនុជក្សត្រីចូលរាជវាំង...។ ព្រះអង្គសេនាកុត្តរាជទ្រង់ទតឃើញ កេសរសុមន្ទាមកដល់ ក៏ឱបគ្នាសោយសោកយ៉ាងខ្លាំងរហូតដល់សន្ទប់បាត់ស្មារតី...។ បន្ទាប់ពីកីលៀងបានយកទឹកមកប្រោះព្រំមក ក៏ដឹងព្រះកាយឡើងវិញ ទ្រង់សួរសុខទុក្ខអនុជក្សត្រី។ កេសរសុមន្ទា ក៏បានរៀបរាប់ពីដំណើរដែលស័ង្ខសិល្បជ័យបានទៅច្បាំងយកពីយក្ស និងនាគមកហើយក៏ត្រូវមានគ្រោះធ្លាក់ចូលជ្រោះបាត់ខ្លួនរហូត...។ ព្រះអង្គសេនាកុត្តរាជទ្រង់សណ្តាប់រួចក៏ជឿជាក់ថា ស័ង្ខសិល្បជ័យពិតជាបុត្រដែលមានតេជបារមីពិតប្រាកដមែន ទ្រង់សោយសោក

អត្ថបទដោយ៖ មាស សុភាព

នឹកស្រណោះដល់បុត្រា។ ចំណែកស្ដេចពាលទាំងប្រាំមួយឃើញដូច្នោះស្រឡាំងកាំង មិននឹកស្មានថាកេសរសុមន្ទាមានកលល្បិចដូច្នេះសោះ ទើបទូលបិតាវិញថា: “ព្រះមាតុច្ឆានឹកប្ដីពេក ទើបរវើរវាយនិយាយមិនត្រូវ...តាមពិតពួកខ្ញុំទេដែលទៅច្បាំងពីយក្សមក មិនមានស័ង្ខសិល្បជ័យឯណាទេ ហើយតើពេលនេះបិតាទ្រង់ព្រះតម្រិះយ៉ាងណា? ព្រោះថាបិតាបានប្រាប់ថាឲ្យបុត្រយកមាតុច្ឆាមកនឹងប្រគល់រាជសម្បត្តិឲ្យគ្រប់គ្រង”។

ព្រះអង្គសេនាកុត្តរាជទ្រង់សណ្ដាប់រួចមានបន្ទូលថា: “បុត្រអើយ! ពេលនេះមិនទាន់ថាអ្វីបានទេ ព្រោះបុត្រនិយាយផ្សេងចំណែកមាតុច្ឆានិយាយផ្សេង...”។ ក្រោយពីបានសំណេះសំណាលរួចមក ព្រះអង្គសេនាកុត្តរាជទ្រង់ចាត់ចែងឲ្យរៀបចំរាជវាំង ដើម្បីធ្វើពិធីថ្វាយព្រះពរដល់ក្សត្រីទាំងពីរអង្គ ដោយមានមន្ត្រីតូចធំជាច្រើនមកចូលរួម។

និយាយពីឈ្នួញសំពៅបើកតាមឆ្នេរ ដែលកេសរសុមន្ទាដាក់ស្បៃផ្សង ហើយក៏ឃើញស្បៃនិងស្នៀតសក់គិតថា: “របស់នេះមានតម្លៃណាស់ តើនរណានឹងយកមកទុកចោលទីនេះ?” គិតហើយឈ្នួញក៏រើសស្បៃដែលកេសរសុមន្ទាបានផ្សង គឺពេលដែលឈ្នួញសំពៅទៅដល់នគរបញ្ចាលចំពេលដែលព្រះអង្គសេនាកុត្តរាជរៀបចំពិធីចងដៃអនុជក្សត្រី។

ឈ្នួញសំពៅគិតថា តើនឹងបានអ្វីទៅថ្វាយក្សត្រី ឲ្យសមព្រះកិត្តិយសក្សត្រីគិតចុះឡើងគឺមានតែស្បៃ និងស្នៀតសក់យកទៅថ្វាយព្រះអង្គសេនាកុត្តរាជ។ ព្រះនាងកេសរសុមន្ទាទតឃើញ ស្បៃ ណិងស្នៀតសក់ដូច្នោះ ក៏ទូលព្រះរៀបថា: “ស្បៃ និងស្នៀតសក់នេះហើយដែលខ្ញុំបានផ្សង...”។ ស្ដេចស្ដាប់រួចហើយទ្រង់
គិតក្នុងចិត្តថា បុត្ររបស់ទ្រង់បានរួចជីវិតហើយ។

លុះចប់ពិធី ទ្រង់បានចាត់ឲ្យរៀបប្រាសាទប្រាំពីរជាន់ ឲ្យកេសរសុមន្ទានិងសុពណ៌ទេវីគង់នៅ។ កេសរសុមន្ទា និងបុត្រីកាលរស់នៅក្នុងប្រាសាទហើយ ដោយចេះតែនឹងរលឹកដល់បុត្រស័ង្ខសិល្បជ័យ ហើយទ្រង់សោយសោកជារៀងរាល់ថ្ងៃ...។ ស្ដេចពាលទាំងប្រាំមួយក៏យកលេសទូលបិតាថា: “ក្សត្រីទាំងពីរកើតទុក្ខព្រោះនឹកប្ដី ឥឡូវមិនដឹងឆ្កួតឬជាទេ គួររកមេមត់មកបញ្ចាន់”។ ស្ដេចសណ្ដាប់ហើយក៏ឲ្យរកពេទ្យ ឬមេមត់មកបញ្ចាន់ តែត្រូវកេសរសុមន្ទាវាយត្រូវយ៉ាងដំណំ ថែមទាំងនិយាយថា: “អញគ្មានឈឺអីទេ មក

ចង់ដៃអញធ្វើអ្វី?"។ គ្រូពេទ្យនិងមេមត់ទាំងអស់ខ្លាចរត់លែងហ៊ានមកទៀត។ អាមាត្យក៏ទៅក្រាបទូលស្តេចៗ ទ្រង់គ្រោធជាខ្លាំងថា: "អញខំលំបាកទៅយកវាមកស្មានថាគាប់ ដឹងអីវាឆ្កួតអាល័យប្តីទាំងអស់គ្នា បើដូច្នោះសង់ខ្ទមឲ្យវារស់នៅក្រៅវាំងទៅប្រសើរជាង"។ លុះកន្លងពេលក្រោយមក ព្រះរាជាទ្រង់យាងចេញទៅព្រះពោងដោយមានអាមាត្យគាល់ផង។ កាលនោះមានដីងចក់មួយធ្លាក់ចំលើភ្លៅព្រះអង្គ។ ព្រះអង្គក៏អញ្ជើញហោរាមកគន់គូរមើល ហោរាទាំងអស់ទូលថា: "ទ្រង់នឹងបានយល់បុត្រ ដែលមានឫទ្ធិចេស្តាលើសគេទាំងជម្ពូទ្វីប ឥតមានគូរប្រៀបឡើយ"។ ព្រះរាជាទ្រង់សណ្តាប់រួចត្រេកអរពេកក្រៃ ទ្រង់ប្រទានមាសជាច្រើនដល់ហោរា។ បន្ទាប់មកទ្រង់ក៏យាងទៅរកកេសរសុមន្ទា ទ្រង់មានបន្ទូលថា "តើប្អូនយំដោយសារនឹកប្តី ឬមួយយ៉ាងណា?"។ កេសរសុមន្ទាសណ្តាប់រួចក៏មានបន្ទូលថា: "បងនេះ ក៏ព្រួយពីរឿងហ្នឹងដែរ..."។ បន្ទាប់មកព្រះរាជា ក៏ត្រាស់បញ្ជាឲ្យអាមាត្យ ទៅមើលដល់មណ្ឌលស័ង្ខសិល្បជ័យ។ អាមាត្យក៏បានទៅដល់ ហើយលបមើលឃើញថាអស្ចារ្យពេកក្រៃ ដោយឃើញស័ង្ខសិល្បជ័យគង់លើរាជសីហ៍ ហើយមានទេពតាហែហមជាច្រើន។ អាមាត្យបានឃើញដូច្នោះហើយ ក៏ប្រញាប់ត្រលប់ទៅទូលព្រះរាជាវិញ។ កេសរសុមន្ទា និងសុពណ៌ទេវី ក៏ក្រាបលាព្រះរាជាទៅមុន ព្រះអង្គសេនាកុត្តរាជផ្តាំថា: "យើងមកទីនេះនឹងទទួលបុត្រ ត្រលប់ទៅនគរវិញ"។ ក្សត្រីកេសរសុមន្ទានិងបុត្រីយាងតាមអាមាត្យ រហូតទៅដល់មណ្ឌលស័ង្ខសិល្បជ័យ ឃើញដាក់ជាក្អួយមែនក៏ចូលក្នុងមណ្ឌល ហើយបន្ទូលហៅថា: "នែ! ចៅស័ង្ខសិល្បជ័យមកអាយឆាប់ៗ ម្តាយបែកពីបុត្រយូរហើយ"។ ស័ង្ខសិល្បជពយព្ទសម្លេងងាកមើល យល់ជាក់ព្រះមាតុច្ឆាទើបយាងចុះចាករាជសីហ៍ឱបព្រះមាតុច្ឆា សោយសោករៀបរាប់ទាំងអស់គ្នា។ ស័ង្ខសិល្បជ័យបានប្រាប់មាតុច្ឆាថា: "ពួកស្តេចពាលទាំងនោះប្រានខ្ញុំធ្លាក់ជ្រោះ តែបានព្រះឥន្ទ្រមកជួយនិងយកទឹកសុរាអម្រឹតពីសួគ៌ាមកប្រោះព្រំ ហើយនាំមកដាក់ដល់មណ្ឌលវិញ"។ បន្ទាប់មកស័ង្ខសិល្បជ័យក៏នាំព្រះមាតុច្ឆាទៅជួបមាតាទាំងពីរ ហើយក៏បានណែនាំ ឲមាតាបានស្គាល់មាតុច្ឆាដែលខ្លួនបានទៅយកពីយក្ស។

កេសរសុមន្ទាបានរៀបរាប់ថា: "ពេលនេះព្រះរៀមសេនាកុត្តរាជ បានយាងមកដល់ព្រៃហើយ នឹងមកទទួលបុត្រស័ង្ខសិល្បជ័យ និងមហេសីចូលនគរវិញ..."។ ព្រះនាងបទុមា

អត្ថបទដោយ៖ មាស សុភាព

ស្ដាប់រួចហើយថា: "ប្អូនអើយ! ប្អូនមករកបងនេះមិនថា ដ្បិតប្អូននិរទោស ចំណែកព្រះអង្គវិញនោះ ទ្រង់បានបំបរបង់ពួកយើងហើយ ទ្រង់ថាយើងនេះចង្រៃពុំមានសណ្ដោសប្រណីអ្វីឡើយ ឥឡូវយើងបានសុខស្រួល ទើបស្ដេចមកទទួលយើងទៅវិញ សូមប្អូនជួយគិតផងចុះ"។ កាលនោះទាំងកេសរបុប្ផាក៏ពោលពាក្យទាំងខឹងដែរ។ កេសរសុមន្ទាយល់ម្ចាស់បងខឹងដូច្នោះក៏លោម សុពណ៌ទេវីនិងស័ង្ខសិល្បជ័យក៏បានលោមមាតាទាំងពីរដែរថា: "បំណាច់ព្រះអង្គខំយាងពីឆ្ងាយមករកហើយ សូមមាតាទាំងពីរឈប់ខឹងទៅ"។ បទុមានិងកេសរបុប្ផា ដោយបុត្រទាំងពីរលោមច្រើនដងច្រើនគ្រាពេក ក៏ទន់ចិត្តព្រមតាម ទើបស័ង្ខសិល្បជ័យឃាត់មាតុច្ឆាកុំអាលទៅទូលបិតាថ្វី ចាំខ្ញុំរៀបចំមណ្ឌលសិន...។

រួចស្រេចស័ង្ខសិល្បជ័យអង្គព្រះពោធិសត្វ ក៏ផ្សងថា: "បើអង្គអញបានត្រាស់ជាព្រះពុទ្ធស្បលោកា នាំសត្វអសង្ខៃយ្យដាក់ដល់និព្វានមែននោះ សូមទេវតាសោឡសសួគ៌ាមេត្តាប្រោសប្រាណ ជួយជាបរិវារពេញក្នុងមណ្ឌលនេះនាពេលនេះហោង"។ ការផ្សងរបស់ស័ង្ខសិល្បជ័យបណ្ដាលឲ្យក្ដៅដល់ព្រះឥន្ទ្រ ទ្រង់បើកព្រះទិព្វចក្ខុទត ទើបដឹងថាស័ង្ខសិល្បជ័យត្រូវការឲ្យជួយ ទើបទ្រង់ប្រកាសអស់ទេវតា ពួកកិន្នរ ឲ្យចុះទៅនាមណ្ឌលស័ង្ខសិល្បជ័យក្នុងពេលនេះ។ លុះរៀបចំរួចស្រេចហើយ ស័ង្ខសិល្បជ័យក៏បានចាត់ឲ្យព្រះវិស្វកម្មទៅទទួលព្រះបិតាមក...។ នៅពេលដែលព្រះអង្គសេនាកុត្តរាជយាងមកដល់ហើយ ស័ង្ខសិល្បជ័យចាត់អស់ទេពកញ្ញាឲ្យយាងសម្ដេចព្រះបិតាចូលក្នុងមណ្ឌល។ ព្រះអង្គសេនាកុត្តរាជ ទ្រង់ទតមើលទិព្វស្ថានដ៏អស្ចារ្យ ហើយទ្រង់ព្រះចិន្ដាថា: "នេះជាស្ថានទិព្វអស្ចារ្យ ភ្នែកអញថ្ងៃនេះហៅមានភ័ព្វ"។ ទ្រង់មិនស្គាល់រាជបុត្រ សូម្បីតែបទុមា និងកេសរបុប្ផាក៏ប្លែកដែរ។ ស័ង្ខសិល្បជ័យ ទ្រង់យាងបិតាឡើងគង់លើទិព្វអាសនៈ ហើយបទុមានិងកេសរបុប្ផាក៏បានក្រាបបង្គំព្រះអង្គសេនាកុត្តរាជ។ ព្រះអង្គសេនាកុត្តរាជទ្រង់មានបន្ទូល:

**(សូមរង់ចាំតាមដានរឿងស័ង្ខសិល្បជ័យភាគទី១២ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព